គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

លេខ១២៥៥/១៥.សស.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ ថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ ២០១៥

# សេចក្តីសម្រេច

## ស្តីពីការកែសម្រួលតួនាទី ភារកិច្ច សិទ្ធិអំណាច រចនាសម្ព័ន្ធចាត់តាំង និងរបៀបរបបធ្វើការ របស់គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាល

**យោង**៖-សេចក្តីកំណត់លេខ ១០ ចុះថ្ងៃទី ២០/១០/១៩៩២ ស្តីពីតួនាទី ភារកិច្ច សិទ្ធិអំណាច អង្គការចាត់តាំងរបស់គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាល។

-សភាពការណ៍ សំណូមពរនិងសេចក្តីត្រូវការចាំបាច់ចំពោះមុខនិងយូរអង្វែងរបស់គណបក្ស។

-ស្មារតីអង្គប្រជុំគណប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនាថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ២០១៥។

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

## សម្រេច

**ប្រការ១៖** កែសម្រួលតួនាទី ភារកិច្ច សិទ្ធិអំណាច រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការរបស់គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាល ដូចខាងក្រោម៖

**ក.តួនាទី**

-គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការណ្តាល ជាស្ថាប័នសេនាធិការរបស់គណៈកម្មាធិការកណ្តាលទទួលខុសត្រូវក្នុងការកសាងផែនការ និងចាត់វិធានការរកចំណូល ដោះស្រាយចំណាយថវិកាការថែរក្សា គ្រប់គ្រងការធ្វើអាជីវកម្ម សេវាកម្ម នូវចលនទ្រព្យ និងអចលនទ្រព្យរបស់គណបក្ស ស្របតាមច្បាប់ និងមានប្រសិទ្ធភាព។

**ខ.ភារកិច្ច៖**

១-កសាងផែនការហិរញ្ញវត្ថុ ថវិកាគណបក្ស និងផែនការចំណូលចំណាយ។

២-អនុវត្តដំណើរការសកម្មភាព ផលិតកម្ម អាជីវកម្ម សេវាកម្ម ប្រមូលគ្រប់គ្រងប្រើប្រាស់ភាគទានប្រចាំខែរបស់មន្ត្រី និងសមាជិកគណបក្ស ចាត់ចែងរក និងគ្រប់គ្រងវិភាគទាន អំណោយស្ម័គ្រចិត្តពីសប្បុរសជន។

៣-ត្រួតពិនិត្យ និងបែងចែកចំណូលគណបក្សឲ្យបានសមស្របដើម្បីធានាចំណាយថវិកាគណបក្សឲ្យមានប្រសិទ្ធភាព។

៤-រក្សាទុកសំណុំឯកសារ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរបស់គណបក្ស។

៥-វាយតម្លៃសភាពការណ៍ការងារគ្រប់គ្រងចំណូល ចំណាយហិរញ្ញវត្ថុ ថវិកាគណបក្ស ការថែ រក្សាការពារ ទ្រព្យសម្បត្តិគណបក្ស និងលើកសំណើ ជូនគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាលសម្រេច អំពីគោលការណ៍ការងារហិរញ្ញវត្ថុ ថវិកាគណបក្ស។

៦-បណ្តុះបណ្តាលជូរមន្ត្រីជំនាញហិរញ្ញវត្ថុ។

៧-សិក្សាស្រាវជ្រាវអំពីគោលនយោបាយនានា សម្រាប់មន្ត្រី បុគ្គលិក កម្មករបម្រើការងារក្នុងអង្គការចាត់តាំងនានារបស់គណបក្សឲ្យមានសង្គតិភាពជាមួយបៀវត្សមន្ត្រីរាជការ។

**គ.សិទ្ធិអំណាចៈ**

-បើកផ្តល់ចំណាយក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន និងតាមការសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល។

-ចុះហត្ថលេខាលើសំណុំលិខិត ឯកសារបញ្ជាចំណូល ចំណាយរបស់ថ្នាក់កណ្តាល។

-ចាត់ចែងប្រើប្រាស់ទ្រព្យសម្បត្តិគណបក្សស្របតាមច្បាប់ និងត្រួតពិនិត្យរាល់ការចំណាយថវិកាតាមការចាំបាច់។

-ណែនាំ និងត្រួតពិនិត្យស្ថាប័នជុំវិញគណៈកម្មាធិការកណ្តាល និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ធ្វើការបូកសរុប និងកសាងផែនការ ទិសដៅការងារហិរញ្ញវត្ថុថវិកាគណបក្សប្រចាំឆ្នាំ។

-រួមជាមួយគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល លើកយោបល់ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ពិនិត្យសម្រេច អំពីក្របខ័ណ្ឌនៃស្ថាប័នជុំវិញគណៈកម្មាធិការកណ្តាល និងស្ថាប័នគណបក្សថ្នាក់ក្រោម ។

-ចុះត្រួតពិនិត្យផ្ទាល់ការអនុវត្តការងារជំនាញហិរញ្ញវត្ថុថវិកា និងការគ្រប់គ្រងអចលនទ្រព្យនៃគណបក្សរាជធានី ខេត្ត រួមទាំងការពិនិត្យលើឯកសារពាក់ព័ន្ធ។

-កោះអញ្ជើញប្រធាន ឬតំណាងគណៈកម្មាធិការហិរញ្ញវត្ថុគណបក្សរាជធានី ខេត្ត ចូលរួមប្រជុំការងារជំនាញហិរញ្ញវត្ថុ។

**ឃ.រចនាសម្ព័ន្ធ**

-គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាលរួមមាន ប្រធាន១រូប អនុប្រធាន និង សមាជិកមួយចំនួនតាមការចាំបាច់។

-គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាល មានមន្ទីរ និងនាយកដ្ឋានចំណុះចំនួន២ (មានឧបសម្ព័ន្ធស្តីពីរចនាសម្ព័ន្ធចាត់តាំងភ្ជាប់មកជាមួយ)៖

+មន្ទីរគណៈកម្មាធិការហិរញ្ញវត្ថុ ដែលរួមមានបេឡា និងការិយាល័យចំនួន២ គឺ៖ ការិយាល័យរដ្ឋបាលនិងបូកសរុប និងការិយាល័យឯកសារ។

+នាយកដ្ឋានគណនេយ្យ និងត្រួតពិនិត្យ ដែលរួមមានការិយាល័យចំនួន ២ គឺ៖ ការិយាល័យគណនេយ្យ និងការិយាល័យត្រួតពិនិត្យ។

+នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិគណបក្ស និងហិរញ្ញកិច្ច ដែលរួមមានការិយាល័យចំនួន ២ គឺ៖ ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិគណបក្ស និងការិយាល័យហិរញ្ញកិច្ច។

-គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាល អាចជ្រើសរើសមន្ត្រីក្របខ័ណ្ឌជំនួយការមួយចំនួនតាមការចាំបាច់នៃការងារ ស្របតាមការកំណត់របស់គណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាល។

**ង.របៀបរបបធ្វើការ**

-គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាលធ្វើការងារតាមរបបប្រធាន។ ប្រធាន ទទួលខុសត្រូវដឹកនាំរួម។ អនុប្រធានទទួលខុសត្រូវជួយប្រធានដឹកនាំការងារមួយចំនួនតាមការប្រគល់ភារកិច្ចរបស់ប្រធាន និងជំនួសប្រធាននៅពេលដែលប្រធានអវត្តមាន។

-ក្នុងករណីចាំបាច់បន្ទាន់ ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការហិរញ្ញវត្ថុដែលបានទទួលសិទ្ធិដោះស្រាយការងារប្រចាំថ្ងៃ មានសិទ្ធិសម្រេចដោះស្រាយថវិកា ក្នុងកម្រិតកំណត់ដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។

-គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាល ត្រូវធ្វើរបាយការណ៍អំពីសភាពការណ៍ហិរញ្ញវត្ថុ ចំណូល ចំណាយ ប្រចាំខែ ត្រីមាស ឆមាស ជូនប្រធានគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងរបាយការណ៍ប្រចាំឆ្នាំ ជូនប្រធាន អនុប្រធានគណបក្ស។

-ការដោះស្រាយប្រតិបត្តិការហិរញ្ញវត្ថុ ចំណាយដោយចៃដន្យក្រៅគំរោងផែនការ ត្រូវមានយោបល់សម្រេចជាគោលការណ៍ ពីគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល។

-ផ្អែកតាមសេចក្តីសម្រេចនេះ គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាល ត្រូវកសាងបទវិន័យផ្ទៃក្នុងរបស់ខ្លួន និងមន្ទីរ នាយកដ្ឋាន អង្គភាពចំណុះ សំដៅធានាអនុវត្តឲ្យបានល្អនូវរាល់ភារកិច្ចដែលបានកំណត់ ។

**ប្រការ២៖** សេចក្តីសម្រេច ឬសេចក្តីកំណត់ពីមុន ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣៖** ខុទ្ទកាល័យ គណៈចាត់តាំង គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្ស ដែលពាក់ព័ន្ធ ត្រូវប្រតិបត្តិតាមសេចក្តីសំរេចនេះ។

**ជ.គណៈអចិន្ត្រៃយ៍**

**ប្រធាន**

**ហ៊ុន សែន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្ដាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

# ឧបសម្ព័ន្ធ

## ស្ដីពីរចនាសម្ព័ន្ធចាត់តាំងរបស់
## គណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការកណ្ដាល




ភ្នំពេញ, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៥
ជ.គណៈអចិន្ត្រៃយ៍ ក.
ប្រធាន

ហ៊ុន សែន